ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗ របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិក អាជ្ញាធរសវនកម្មជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ឆ្នាំ ២០០២ ។
-តាមសំណើរបស់អគ្គសវនករ

<u>សំរេច</u>

មាត្រា ១ : អនុក្រឹត្យនេះកំណត់ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិ ។

មាត្រា ២ : ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិត្រូវកត់ត្រាក្នុងជំពូក ១០ នៃមាតិកាថវិការដ្ឋ ។

មាត្រា ៣ : អគ្គសវនករ អគ្គសវនកររង អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបានទទួលប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗប្រចាំខែតាមការកំណត់ដូចខាងក្រោមចាប់ពីថ្ងៃទទួលភារកិច្ច :

www.pheakdeylaw.com

- អគ្គសវនករត្រូវបាន : ៦.៣៣៧.០០០៛
- អគ្គសវនកររងត្រូវបាន : ៤.៩៣០.០០០៛
- អគ្គលេខាធិការត្រូវបាន : ៣.៦៤១.៦០០៛
- អគ្គលេខាធិការរងត្រូវបាន : ២.៩៨០.១០០៛

មាត្រា ៤ : ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិ ដែលមិនបានចែងក្នុងប្រការ ៣ ត្រូវស្ថិតនៅក្រោមការពិនិត្យ និងសំរេចរបស់អគ្គសវនករ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២[illegible] ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
អគ្គសវនករ

អ៊ុត ឈន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com